ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មិថុនា ២០០៧ / June 2007

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភីម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត សំរាប់វិស័យកាត់ដេរ កើន ៤១% ធៀបនឹងត្រីមាសមុន ដល់ ៣៦,៦លានដុល្លារ ក្នុងត្រីមាសទីមួយ ឆ្នាំ២០០៧ ។ គំរោងខាងកាត់ដេរចំនួន ៥ ត្រូវបានអនុម័ត ដែលនឹងស្រូបយកកម្មករបន្ថែមចំនួន ២០.១៩៩នាក់ ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ គំរោងវិនិយោគខាងវិស័យកាត់ដេរបានអនុម័ត កើនឡើង ២០% ។

Fixed asset investment approvals for the garment sector increased by 41 percent from the previous quarter to USD 36.6 m in the first quarter 2007. There were five garment project approvals, which will absorb an additional 20,199 workers. Compared to the same quarter in 2006, garment investment approvals rose by 20 percent.

**Fixed Asset Investment Approvals by CDC for the Garment Sector**

2004 Q1–2007 Q1




*Including expansion projects*

Source: Council for the Development of Cambodia

នៅខែមីនា ២០០៧ ចំនួនភ្ញៀវមកដល់កម្ពុជាសរុបមាន ១៧៨.៧៥១នាក់ រឺកើនឡើង ០,៩% ធៀបនឹងខែមុន ។ ភ្ញៀវមកដល់ក្នុងបំណងសំរាកលំហែ ថយចុះ ១,៨% មកត្រឹម ១៥៨.៩៩៩នាក់ ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ភ្ញៀវមកសំរាកលំហែកើនឡើង ២៧% ។

In March 2007, total visitor arrivals to Cambodia were 178,751, an increase of 0.9 percent from the preceding month. Arrivals by visitors on holiday declined by 1.8 percent to 158,999 from the preceding month. Arrivals by visitors on holiday increased by 27 percent from the same month in 2006.

**Cambodia: Foreign Visitor Arrivals**

January 2006–March 2007




Source: Ministry of Tourism

ការអនុមតិគំរោងសាងសង់នៅភ្នំពេញ កើនមួយជាពីរ ដល់ ២៦,៧លានដុល្លារ នៅខែមីនា ឆ្នាំ២០០៧ បើធៀបនឹងខែមុន ។ ការអនុមតិសំណង់ផ្ទះល្វែង កើនឡើង ៥ដង នៅក្នុងខែមុន ដល់ ២០,៤លានដុល្លារ រីឯសំណង់ភូមិគ្រឹះ និងផ្ទះ កើន ៥,៦% ដល់ ២,៧លានដុល្លារ ។ ប៉ុន្តែធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការអនុមតិគំរោងសាងសង់សរុបធ្លាក់ចុះ ២៣% ។

Construction approvals in Phnom Penh doubled to USD 26.7 m in March 2007, compared to the preceding month. Construction approvals for flats increased by five times the value of the previous month to USD 20.4 m, and villa & house constructions rose by 5.6 percent to USD 2.7 m. Compared to the same month in 2006, however, total construction approvals dropped by 23 percent.

**Phnom Penh: Value of Construction Approvals**

January 2006–March 2007




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់កំចី

# Consumer Prices and Interest Rates on Loans

នៅខែមេសា ២០០៧ ថ្លៃទំនិញទូទៅនៅភ្នំពេញ កើន ០,៨% ធៀបនឹងខែមុន ។ ថ្លៃម្ហូបអាហារភេសជ្ជៈនិងថ្នាំជក់ និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ១,៤% និង ១,០% ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ថ្លៃទំនិញទូទៅ កើន ៤,០% ។ ក្នុងនោះ ថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ កើន ៥,៥% ឯថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ៥,១% ។

In April 2007, Phnom Penh's overall prices increased by 0.8 percent from the previous month. Food, beverage & tobacco prices, and transportation & communication costs were up by 1.4 percent and 1.0 percent, respectively. Compared to the same month in 2006, the prices of all items rose by 4.0 percent. Food, beverage & tobacco, and transportation & communication rose by 5.5 percent and 5.1 percent, respectively.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

January 2006–April 2007




Source: National Institute of Statistics

នៅខែឧសភា ២០០៧ ថ្លៃសាំងជាមធ្យមលក់បាន ៣៨៨៤រៀល/លីត្រ រឺ កើន ២,១% ធៀបនឹងខែមុន ។ ថ្លៃម៉ាស៊ូត កើន ០,៦% ដោយលក់បាន ៣០៩០រៀល/លីត្រ ។ ប៉ុន្តែ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ទាំងសាំង និងម៉ាស៊ូត ធ្លាក់ថ្លៃអស់ ១,៤% ។

Gasoline prices averaged 3884 riels/ℓ in May 2007, a rise of 2.1 percent from the previous month. The price of diesel increased by 0.6 percent, trading at 3090 riels/ℓ. Compared to the same month in 2006, however, both gasoline and diesel prices declined by 1.4 percent.

**Phnom Penh: Gasoline & Diesel Prices**

March 2006–May 2007




Sources: CDRI and National Institute of Statistics

អត្រាការប្រាក់លើប្រាក់កំចីធនាគារនៅថេរ ចាប់តាំងពីឆ្នាំ២០០៥ ។ នៅខែមីនា ២០០៧ អត្រាការប្រាក់លើកំចីជាប្រាក់រៀល របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស គឺ ១៨% រីឯអត្រារបស់ធនាគារកាណាឌីយ៉ា និងអេស៊ីលីដា គឺ ២៤% ។ សំរាប់កំចីជាប្រាក់ដុល្លារ ធនាគារទាំងបី មានអត្រាដូចគ្នា គឺ ១៨% ។

Interest rates on 12-month bank loans have been stable since 2005. In March 2007, interest rates on riel loans offered by the Foreign Trade Bank (FTB) was 18 percent, while the rate at Canadia Bank and ACLEDA Bank was 24 percent. On US dollar loans, the three banks offered the same rate, 18 percent.

**Interest Rate on 12-Month Bank Loans**

(As of March 2007)




Source: National Bank of Cambodia.

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែឧសភា ២០០៧ ប្រាក់រៀលប្តូរបាន ៤០៧៤,៦រៀល/ដុល្លារ រឺធ្លាក់ចុះអស់ ០,៤% ធៀបនឹងខែមុន ។ ប៉ុន្តែធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារ ។

In May 2007, the riel traded at 4074.6 riels/USD, a depreciation of 0.4 percent from the previous month. Compared to the same month in 2006, however, the riel appreciated by 0.9 percent against the US dollar.

**Riels per US Dollar**
March 2006–May 2007




Sources: National Bank of Cambodia and CDRI

នៅខែឧសភា ២០០៧ ប្រាក់រៀលធ្លាក់ថ្លៃ ៣,២% ទល់នឹងប្រាក់បាតថៃធៀបនឹងខែមុន ដោយប្តូរបាន ១១៩,៦រៀល/បាត ។ អត្រាប្តូរប្រាក់រៀលទល់នឹងប្រាក់ដុងវៀតណាម គឺ ២៤,៧រៀល/១០០ដុង រឺ ធ្លាក់ថ្លៃ ០,៦% ។ ធៀបនឹងខែឧសភា ២០០៦ តំលៃប្រាក់រៀលធ្លាក់ចុះ ៩,៦% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែកើនឡើង ១,២% ធៀបនឹងប្រាក់ដុងវៀតណាម ។

The riel depreciated by 3.2 percent against the Thai baht in May 2007 compared to the preceding month, trading at 119.6 riels/baht. The exchange rate of the riel against the Vietnamese dong was 24.7 riels per 100 dong, a depreciation of 0.6 percent. Compared with May 2006, the value of the riel fell by 9.6 percent against Thai baht, while with Vietnamese dong, it was up by 1.2 percent.

**Riels per THB & VND**
March 2006–May 2007




Source: CDRI

នៅឆ្នាំ២០០៦ គំរោងប្រាក់កំចីធនាគារពិភពលោក ផ្តល់អោយកម្ពុជាគឺ ១៨,៦លានដុល្លារ ។ គំរោងចំបងៗចំនួន៨ មានតំលៃ ១៦,១លានដុល្លារ គឺមាន គំរោងស្តារជួសជុលបន្ទាន់ក្រោយមានគ្រោះទឹកជំនន់ ការកសាងសមត្ថភាពខាងវិស័យសាធារណៈនិងសេដ្ឋកិច្ច វិស័យសុខាភិបាលនៅកម្ពុជា គំរោងអនាម័យនិងទឹកស្អាតនៅតាមខេត្តនិងជាយក្រុង វិនិយោគនៅជនបទនិងអភិបាលកិច្ចមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធនៅជនបទនិងតាមខេត្ត បណ្តាញអគ្គិសនីនៅជនបទនិងការបញ្ជូនថាមពល និងការគាំទ្រវិស័យអប់រំនៅកម្ពុជា ។

In 2006, World Bank loan project disbursements to Cambodia amounted to USD 18.6 m. Eight main projects accounted for USD 16.1 m: Flood Emergency Rehabilitation, Economic & Public Sector Capacity Building, Cambodia Health Sector, Provincial and Peri-Urban Water and Sanitation, Rural Investment and Local Governance, Provincial and Rural Infrastructure, Rural Electrification and Transmission, and Cambodia Education Sector Support.

**External Development Assistance Disbursement: Loans Development Project to Cambodia**
in 2006




Source: *Monthly Bulletin of Statistics* (MEF)

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

នៅខែមីនា ២០០៧ រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ៣១% ហើយការផ្គត់ផ្គង់រូបិយវត្ថុ (M1) កើនតាមអត្រាប្រចាំឆ្នាំ ៨២% ។ នៅរយៈ១២ខែមុន រូបិយវត្ថុទូទៅ (M2) កើន ៣៧% ធៀបនឹងកំណើន ៣៨% ក្នុងរយៈមួយឆ្នាំ ដល់ខែកុម្ភៈ ឆ្នាំ២០០៧ ។

In March 2007, liquidity (M2) grew at an annualised rate of 31 percent and money supply (M1) increased at an annualised rate of 82 percent. In the previous 12 months, liquidity (M2) grew by 37 percent, compared to growth of 38 percent in the year to February 2007.

**Monetary Survey**
January 2006–March 2007




Source: National Bank of Cambodia

នៅខែមីនា ២០០៧ ឥណទានក្នុងស្រុកកើនតាមអត្រាប្រចាំឆ្នាំ ២១% រីឯឥណទានក្នុងវិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៥០% ។ ក្នុងរយៈ ១២ខែ ដល់ខែមីនា ២០០៧ ឥណទានក្នុងស្រុក កើន ៤៣% ធៀបនឹងកំណើន ២៦% ក្នុងរយៈមួយឆ្នាំ ដល់ខែកុម្ភៈ ឆ្នាំ២០០៧ ។

Domestic credit grew at an annualised rate of 21 percent, while private sector credit grew at an annualised rate of 50 percent in March 2007. Over the twelve months to March 2007, domestic credit grew by 43 percent, compared to growth of 26 percent in the year to February 2007.

**Domestic Credit**
January 2006–March 2007




Source: National Bank of Cambodia

ឥណទានក្នុងវិស័យឯកជន និងទ្រព្យសកម្មបរទេសសុទ្ធ នៅខែមីនា ២០០៧ កើន ៣,៤% ដល់ ៤០៦៧,៧ពាន់លានរៀល និង ១,៥% ដល់ ៨០៥៦,៣ពាន់លានរៀល ។ ឥណទានរបស់រដ្ឋាភិបាល កើន ៤,៥% ដល់ ២៩៨,០ពាន់លានរៀល ហើយបញ្ញើរបស់រដ្ឋាភិបាល កើន ៧,៥% ដល់ ១៤៧៣,៥ពាន់លានរៀល រីឯបំណុលផ្សេងៗទៀត ធ្លាក់ចុះ ០,៤% មកត្រឹម ៣១៥៥,២ពាន់លានរៀល ។ ប្រតិបត្តិការទាំងនេះ បង្កើនរូបិយវត្ថុទូទៅបាន ២,៣% ដល់ ៧៧៩៣,២ពាន់លានរៀល ។

Private sector credit and Net Foreign Assets (NFA) in March 2007 grew by 3.4 percent to KHR 4067.7 bn and 1.5 percent to KHR 8056.3 bn, respectively. Government credit rose by 4.5 to KHR 298.0 bn and government deposits were up by 7.5 percent to KHR 1473.5 bn, while ‘other items’ decreased by 0.4 percent to KHR 3155.2 bn. These operations increased liquidity by 2.3 percent to KHR 7793.2 bn.

**Changes in Monetary Assets**
January 2006–March 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

ការនាំចេញសរុបរបស់កម្ពុជា នៅខែមីនា ២០០៧ ថយចុះ ៤,៧% មកត្រឹម ២៣២,៩លានដុល្លារ ធៀបនឹងការនាំចេញ ២៤៤,២លានដុល្លារ នៅខែមុន។ ការនាំចេញត្រី និងកៅស៊ូ ធ្លាក់ចុះ ២៤% មកត្រឹម ០,២លានដុល្លារ និង ៥១% មកត្រឹម ១,៣លាន ដុល្លារ ឯការនាំចេញសំលៀកបំពាក់ កើន ០,០៣% ដល់ ២២៧,៧លាន ដុល្លារ ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចេញសរុបកើន ១៥% ក្នុងនោះ ការនាំចេញសំលៀកបំពាក់ និងកៅស៊ូ កើន ១៥% និង ២១% រីឯ ការនាំចេញត្រីថយចុះអស់ ៦១% ។

Cambodia's total exports in March 2007 fell by 4.7 percent from USD 244.2 m in the previous month to USD 232.9 m. Fish and rubber exports declined by 24 percent to USD 0.2 m and 51 percent to USD 1.3 m, respectively, while garment exports increased by 0.03 percent to USD 227.7 m. Compared to the same month in 2006, total exports rose by 15 percent; garment and rubber exports increased by 15 percent and 21 percent, respectively, while fish exports declined by 61 percent.

**Cambodia: Main Exports**
January 2006–March 2007




Source: Customs and Excise Department

នៅខែមីនា ២០០៧ ការនាំចូលដែក និងស៊ីម៉ង់ត៍ កើន ៣០% ដល់ ២៦,២ពាន់លានរៀល និង ១៩% ដល់ ២៦,០ពាន់លានរៀល រីឯ ការនាំចូលបារី ធ្លាក់ចុះ ៤៥% មកត្រឹម ១៧,២ពាន់លានរៀល ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចូលដែក និងស៊ីម៉ង់ត៍ កើន ៧១% និង ២៥% រីឯការនាំចូលបារី ធ្លាក់ចុះ ៤៥% ។

In March 2007, steel and cement imports increased by 30 percent to KHR 26.2 bn and 19 percent to KHR 26.0 bn, respectively, while cigarette imports dropped by 45 percent to KHR 17.2 bn from the preceding month. Steel and cement imports rose by 71 percent and 25 percent, respectively, compared to the same month in 2006; whereas, cigarette imports dropped by 45 percent.

**Imports: Cigarettes & Construction Materials**
January 2006–March 2007




Source: Customs and Excise Department

ការនាំចូលសាំង នៅខែមីនា ២០០៧ កើន ២៥% ធៀបនឹងខែមុន ដល់ ១៧.៧២១តោន រីឯការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ១៣% មកត្រឹម ៣៨.៥៨៦តោន ។ តំលៃនៃការនាំចូលសាំងគឺ ២២,៣ពាន់លានរៀល ហើយ តំលៃនៃការនាំចូលម៉ាស៊ូតគឺ ៤២,៥ពាន់លានរៀល ។

Imports of gasoline in March 2007 rose by 25 percent from the previous month to 17,721 tonnes, while diesel imports dropped by 13 percent to 38,586 tonnes. In value, gasoline imports were KHR 22.3 bn and diesel imports were KHR 42.5 bn.

**Imports: Petroleum Products**
January 2006–March 2007




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែធ្នូ ២០០៦ ថវិកាចរន្តមានឱនភាព ៣០,០ពាន់លានរៀល ធៀបនឹងអតិរេក ៥១,០ពាន់លានរៀល នៅខែមុន និងឱនភាព ១៤២,២ពាន់លានរៀល នៅខែដូចគ្នា ឆ្នាំ២០០៥ ។

The current budget deficit was KHR 30.0 bn in December 2006, compared to a surplus of KHR 51.0 bn in the previous month and a deficit of KHR 142.2 bn in the same month in 2005.

**Current Budget Operations**
January 2006–December 2006




*Note: Provisional for2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែធ្នូ ២០០៦ ចំណូលថវិកាចរន្តមាន ៣៦១,៥ពាន់លានរៀល វិកើនឡើង ៥២% ធៀបនឹងខែមុន ។ ចំណូលមិនមែនពន្ធកើនឡើងមួយជាបី ធៀបនឹងខែមុន ដល់ ៩៧,៦ពាន់លានរៀល ។ ពន្ធក្នុងស្រុក និង ពន្ធនាំចេញនាំចូលកើន ១១% ដល់ ៧១,៩ពាន់លានរៀល និង ៣៩% ដល់ ១៩២,០ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណូលថវិកាចរន្តកើនបាន ៣,៤% ។

In December 2006, current budget revenue was KHR 361.5 bn, an increase of 52 percent from the preceding month. Non-tax revenue increased by three times the value of the previous month to KHR 97.6 bn. Domestic taxes, and import and export taxes rose by 11 percent to KHR 71.9 bn and 39 percent to KHR 192.0 bn, respectively. Compared to the same month last year, current budget revenue rose by 3.4 percent.

**Current Budget Revenue**
October 2005–December 2006




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែធ្នូ ២០០៦ ចំណាយថវិកាចរន្តកើនមួយជាពីរ ដល់ ៣៩១,៧ពាន់លានរៀល ធៀបនឹងខែមុន ។ ចំណាយលើរដ្ឋបាលសង្គម រដ្ឋបាលទូទៅ និងរដ្ឋបាលសេដ្ឋកិច្ច កើនឡើងមួយជាបី ធៀបនឹងខែមុន ដល់ ១៧១,០ពាន់លានរៀល, ៧៥,២ពាន់លានរៀល និង ៥០,៧ពាន់លានរៀល ។ ចំណាយលើសន្តិសុខនិងការពារជាតិ ធ្លាក់ចុះ ២,៤% មកត្រឹម ៥៨,៥ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៥ ចំណាយចរន្តធ្លាក់ចុះ ២០% ។

Current budget expenditure in December 2006 doubled to KHR 391.7 bn, compared to the previous month. Spending on social, general and economic administration increased by three times the value in the preceding month to KHR 171.0 bn, KHR 75.2 bn and KHR 50.7 bn, respectively, while spending on defense and security fell by 2.4 percent to KHR 58.5 bn. Compared to the same month in 2005, current expenditure fell by 20 percent.

**Current Budget Expenditure**
October 2005–December 2006




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមីនា ការនាំចេញទំនិញរបស់ US តំបន់អឺរ៉ូ និងជប៉ុនកើនឡើង ។ ការនាំចេញទំនិញរបស់ US កើន ១,៩% ធៀបនឹងខែមុន ដល់ ៩០,១៧ ពាន់លានដុល្លារ រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើន ១,២% ដល់ ១៦៣,៧៣ពាន់លានដុល្លារ ។ នៅខែមីនាដដែល ការនាំចេញទំនិញរបស់ជប៉ុន កើន ១៩% ធៀបនឹងខែមុន ដល់ ៦៣,៤៥ពាន់លានដុល្លារ ។

In March, goods exports of the US, Euro zone and Japan increased. US goods exports rose by 1.9 percent from the previous month to USD90.17 bn, while goods exports from the Euro zone increased by 1.2 percent to USD 163.73 bn. Japan goods exports in March jumped by 19 percent from the previous month, to USD63.45 bn.

**Goods Exports: US, Euro zone & Japan**
March 2006–March 2007




Sources: BEA, Eurostat and JETRO

នៅខែមីនា ចិនមានអតិរេកពាណិជ្ជកម្ម ៦,៨៧ពាន់លានដុល្លារ ធៀបនឹងអតិរេក ២៣,៧៦ពាន់លានដុល្លារ នៅខែកុម្ភៈ ។ អតិរេកតូចជាងមុននេះបណ្តាលមកពីការនាំចូលកើនឡើង ច្រើនជាងការនាំចេញ ។ ការនាំចូលសរុប កើនឡើង ៣១% ធៀបនឹងខែមុន ដល់ ៧៦,៥៥ពាន់លានដុល្លារ រីឯការនាំចេញសរុបកើន ១,៦% ដល់ ៨៣,៤៣ពាន់លានដុល្លារ ។

In March, China recorded a trade surplus of USD6.87 bn, compared to a surplus of USD23.76 bn in February. The smaller surplus was due to a greater increase in imports than exports. Total imports increased by 31 percent from the previous month to USD76.55 bn, while total exports rose by 1.6 percent to USD83.43 bn.

**External Trade: China**
March 2006–March 2007




Sources: National Bureau of Statistics of China

នៅខែមីនា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ១,៩២ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,០០ពាន់លានដុល្លារ នៅខែកុម្ភៈ ។ ទាំងការនាំចេញ និង ការនាំចូលសរុប កើនឡើងយ៉ាងខ្លាំងធៀបនឹងខែមុន ។ នៅខែមីនា ការនាំចេញសរុប កើនដល់ ១៤,៤៥ពាន់លានដុល្លារ ធៀបនឹង ការនាំចេញ ១០,៨២ពាន់លានដុល្លារ នៅខែកុម្ភៈ ។ ការនាំចូលសរុបមានចំនួន ១២,៥៣ពាន់លានដុល្លារ ធៀបនឹង ៨,៨២ពាន់លានដុល្លារ នៅខែកុម្ភៈ ។

In March, Malaysia recorded a trade surplus of USD1.92 bn, compared to USD2.00 bn in February. Both total exports and total imports increased significantly from the previous month. Total exports in March reached USD14.45 bn, up from USD10.82 bn in February. Total imports were USD12.53 bn, up from USD8.82 bn in February.

**External Trade: Malaysia**
March 2006–March 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ក្នុងរយៈមួយឆ្នាំដល់ខែមីនា ថ្លៃទំនិញប្រើប្រាស់នៅ US កើន ២,៨% ។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ និងថាមពល ។ នៅអំឡុងពេលដូចគ្នា អត្រាអតិផរណាមានកំរិត ១,៩% នៅតំបន់អឺរ៉ូ និង -0,១% នៅជប៉ុន ។

US consumer prices increased by 2.8 percent in the year to March. According to the U.S Department of Labor, this increase largely reflected higher charges for food and energy. During the same period, the inflation rate was 1.9 percent in the Euro zone and -0.1 percent in Japan.

**Inflation Rate: US, Euro zone & Japan**

(change from a year ago)




*Note: The latest data available are for March 2007*

Sources: IMF and *The Economist* (May 26th 2007)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើនឡើង ២,៤% ក្នុងរយៈមួយឆ្នាំដល់ខែមីនា ឆ្នាំ២00៧ គឺ ខ្ពស់ជាងកំណើន 0,៨% សំរាប់ខែមុន ។ កំណើនតូចជាងមុននៅខែកុម្ភៈ បណ្តាលមកពីការលើកលែងការបង់ថ្លៃជួលផ្ទះរដ្ឋ។ នៅអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង កើន ៣,៣% និង ២,២% ។

Hong Kong’s consumer prices rose by 2.4 percent in the year to March 2007, higher than the 0.8 percent increase of a month earlier. The significantly smaller increase in February was due to the waiver of public housing rentals by the Housing Authority and Housing Society. During the same period, consumer prices in China and South Korea increased by 3.3 percent and 2.2 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**

(change from a year ago)




*Note: The latest data available are for March 2007*

Sources: IMF and *The Economist* (May 26th 2007)

នៅខែមីនា ២00៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើនឡើង 0,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការអប់រំ ការថែទាំសុខភាព និងការលំហែកំសាន្ត ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាក្នុងរយៈមួយឆ្នាំ មានកំរិត ១,៥% នៅម៉ាឡេស៊ី និង ២,0% នៅថៃ ។

Singapore's consumer price index in March 2007 was 0.7 percent higher than the same month a year earlier. Singapore’s Department of Statistics attributed this to higher costs for food, education, healthcare and recreation. During the same period, the year-on-year inflation rate was 1.5 percent in Malaysia and 2.0 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(change from a year ago)




*Note: The latest data available are for Feb. 2007*

Sources: IMF and *The Economist* (Apr. 19th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែឧសភា ២០០៧ ដុល្លារUS មានការប្រែប្រួលចំរុះទល់នឹងរូបិយវត្ថុចំបងៗ។ ទល់នឹងប្រាក់អឺរ៉ូ ដុល្លារUS ប្តូរបាន ០,៧៤អឺរ៉ូ/ដុល្លារUS គឺគ្មានការប្រែប្រួលទេ ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១២០,៨យ៉េន/ដុល្លារUS រឺ ឡើងថ្លៃ ១,៦% ធៀបនឹងខែមុន ។

In May 2007, the movement of the US dollar was mixed against most major currencies. Against the euro, it traded at 0.74 EUR/USD, showing no change from a month earlier. Against the Japanese Yen, it exchanged at 120.8 JPY/USD, a 1.6 percent gain compared to the preceding month.

**EUR & JPY Per USD**

May 06–May 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែឧសភា ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូង បានឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩២៧,៥៨វ៉ុន/ដុល្លារUS ធៀបនឹង ៩៣០,៦៩វ៉ុន/ដុល្លារUS នៅខែមេសា ២០០៧ ។ ក្នុងអំឡុងពេលដូចគ្នា ដុល្លារហុងកុងមិនមានការប្រែប្រួលទេទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៨២ដុល្លារហុងកុង/ដុល្លារUS ។

In May 2007, the South Korean won slightly appreciated against the US dollar, trading at 927.58 KRW/USD against 930.69 KRW/USD in April 2007. During the same period, the Hong Kong dollar was steady against its US counterpart, trading at 7.82 HKD/USD.

**KRW & HKD Per USD**

May 06–May 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែឧសភា ២០០៧ ដុល្លារសិង្ហបុរីចុះថ្លៃទល់នឹងដុល្លារUS បន្ទាប់ពីបានឡើងថ្លៃ ៧ខែជាប់ៗគ្នា ដោយប្តូរបាន ១,៥១៥ដុល្លារសិង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃ ឡើងថ្លៃបន្តិចដែរទល់នឹងដុល្លារUS ដោយប្តូរបាន ៣២,៤២បាត/ដុល្លារUS រឺឡើងថ្លៃ ០,៧% ធៀបនឹងខែមីនា ឆ្នាំ២០០៧ ។

In May 2007, the Singapore dollar rate fell against the US dollar after appreciating for seven consecutive months. It traded at 1.515 SGD/USD. The Thai baht also slightly advanced against the US dollar, exchanging at 32.42 THB/USD, a 0.7 percent appreciation from March 2007.

**THB & SGD Per USD**

May 06–May 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

ថ្លៃអង្ករពិភពលោក កើនឡើងយ៉ាងទៀងទាត់ក្នុងរយៈ៧ឆ្នាំជាប់ៗគ្នា ពី ២000-២00៦ ។ សន្ទស្សន៍ថ្លៃទំនិញអន្តរជាតិ (IPO) កើនដល់ ១២៧ ពិន្ទុ នៅឆ្នាំ២00៦ ធៀបនឹង ៨៩ពិន្ទុ នៅឆ្នាំ២000 ។ នៅឆ្នាំ២00៦ ថ្លៃអង្ករថៃ 100%B គឺ ២៨២,0៨ដុល្លារUS/តោន ធៀបនឹង ១៨៨,៦៦ដុល្លារUS/តោន នៅឆ្នាំ២000 ។ ថ្លៃអង្ករ USA 2/4 (គ្រាប់វែង ២/៤) គឺ ៣៤៧,៣៨ដុល្លារUS/តោន នៅឆ្នាំ២00៦ ធៀបនឹង ២៣៥,៨២ដុល្លារUS/តោន នៅឆ្នាំ២000 ។

World rice prices have increased steadily over the seven years, 2000–2006. The International Prices Index (IPO) rose to 127 in 2006, up from 89 in 2000. The price of Thai 100%B in 2006 was USD282.08 per tonne, compared to USD188.66 per tonne in 2000. The price of USA 2/4 (long grain 2/4) was USD 347.38 per tonne in 2006, up from USD235.82 per tonne in 2000.

**Rice: International Prices Index & Export Prices**
2000–2006




Sources: Osiriz/InfoArroz and InterRice.

នៅខែឧសភា សណ្តែកសៀង និងពោត ឡើងថ្លៃ ។ សណ្តែកសៀង លក់ថ្លៃ ២៥៥,១៥ដុល្លារUS/តោន ធៀបនឹង ២៤៧,៣២ដុល្លារUS/តោន នៅខែមេសា រីឯពោត លក់ថ្លៃ ១៤៤,៦៤ដុល្លារUS/តោន ធៀបនឹង ១៣៩,៣៥ដុល្លារUS/តោន នៅខែមេសា ។ នៅខែមេសា ប្រេងឆា ឡើងថ្លៃ ១៤% ធៀបនឹងខែមុន ដល់ ៦៤៣,៩៧ដុល្លារUS/តោន ។

In May, the prices of soybeans and maize increased. Soybeans sold at USD255.15 per tonne, up from USD247.32 per tonne in April. Maize was USD144.64 per tonne, up from USD139.35 per tonne in April. In April, the price of palm oil increased by 14 percent from the previous month, to USD643.97 per tonne.

**Prices: Soybeans, Maize & Palm Oil**
May 2006–May 2007




Source: Food and Agriculture Organisation (FAO)

នៅខែឧសភា ប្រេងឆៅ និងសាំង ឡើងថ្លៃ រីឯម៉ាស៊ូត ធ្លាក់ថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៤,៨២ដុល្លារUS/ធុង ធៀបនឹង ៦៤,៤១ដុល្លារUS/ធុង នៅខែមេសា ។ នៅ US Gulf Coast សាំងធម្មតា (អុកតាន ៨៧) ឡើងថ្លៃ ១0% ធៀបនឹងខែមុន ដល់ ៦១,១៦សេន/លីត្រ ។ ម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) ធ្លាក់ថ្លៃ អស់ ២,៧% ធៀបនឹងខែមុន មកត្រឹម ៥២,៧៨សេន/លីត្រ ។

In May, the prices of crude oil and gasoline increased, while the price of diesel decreased. The OPEC spot price of crude oil was USD64.82 per barrel, against USD64.41 in April. Regular gasoline (87 octane) prices on the US Gulf Coast rose by 10 percent from the previous month to 61.16 cents per litre. Diesel (low sulphur No.2) on the US Gulf Coast went down by 2.7 percent from the previous month, to 52.78 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
May 2006–May 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

***កម្ពុជាអាចក្លាយជាប្រទេសនាំចេញអង្ករនាំមុខគេនៅឆ្នាំក្រោយ:*** នៅថ្ងៃទី១ ខែឧសភា ប្រព័ន្ធព័ត៌មានក្នុងស្រុក បានផ្សាយថា កម្ពុជានឹងអាចសំរេចមហិច្ឆតារបស់ខ្លួនដើម្បីក្លាយទៅជាអ្នកនាំចេញអង្ករនាំមុខគេ នៅឆ្នាំ២០០៨ ប្រសិនបើមានទុនគ្រប់គ្រាន់សំរាប់ទិញស្រូវពីកសិករក្នុងស្រុក ។ សារព័ត៌មាន *រស្មីកម្ពុជា* បានចុះផ្សាយប្រសាសន៏របស់លោក ពូ ពុយ ប្រធានសមាគមរោងម៉ាស៊ីនកិនស្រូវកម្ពុជា ថា នាបច្ចុប្បន្ន រោងម៉ាស៊ីនកិនស្រូវកម្ពុជា ត្រូវការ ៨០លានដុល្លារ សំរាប់ប្រមូលទិញស្រូវពីកសិករ ដើម្បីបង្កើនស្តុកសំរាប់ផលិតអង្ករ ។

លោក ពុយ បានបន្ថែមថា ជារៀងរាល់ឆ្នាំ កសិករកម្ពុជានាំចេញស្រូវជាង ១លាន តោន ជាពិសេសទៅថៃ និងវៀតណាម ។ យើងត្រូវការប្រហែល ៨០លានដុល្លារ ប៉ុន្តែយើងប្រមូលទុនបានតែ ១០លានដុល្លារប៉ុណ្ណោះ ។ បើសិនយើងមានទុនគ្រប់គ្រាន់ យើងអាចនាំចេញអង្ករ ទៅទីផ្សារពិភពលោក នៅឆ្នាំ២០០៨ រឺ ២០០៩ ។ គាត់បញ្ជាក់ថា រោងម៉ាស៊ីនកិនស្រូវ ២៨០កន្លែង នៅក្នុងប្រទេស ដែលមានទុនជាមធ្យមពី ៣ ម៉ឺនដុល្លារ ទៅ ១០ ម៉ឺនដុល្លារ នៅពេលនេះ អាចទិញនិងស្តុកស្រូវបានគ្រប់គ្រាន់សំរាប់តែបំរើទីផ្សារក្នុងស្រុក និងនាំចេញក្នុងទ្រង់ទ្រាយ តូចប៉ុណ្ណោះ ។

ប្រជាជនកម្ពុជា ជាង ៨០% ជាកសិករ ។ ពួកគេជាទូទៅតែងទទួលបានអំណោយផលពីអាកាសធាតុ ហេតុនេះអាចធ្វើស្រូវបានលើសតំរូវការដល់ជាង ១លានតោន/ឆ្នាំ ប៉ុន្តែរហូតមកដល់ពេលនេះ ពួកគេមិនបាននាំចេញអង្ករច្រើនដូចប្រទេសផ្សេងទៀតទេ ដោយសារកង្វះទុន ។

***ប្រទេសកម្ពុជាទទួលបាន គំរោងជួយអ្នកក្រនៅជនបទ:*** មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៏កសិកម្មនៃអង្គការសហប្រជាជាតិ (IFAD) បានប្រកាសថានឹងជួយឧបត្ថម្ភជាគំរោងអភិវឌ្ឍន៏ថ្មីមួយមានទឹកប្រាក់ ១១,៥លានដុល្លារ ដល់កម្ពុជា ក្នុងគោលដៅជួយដល់អ្នកក្រនៅជនបទ ។ លោក Youqiong Wang នាយកគ្រប់គ្រងកម្មវិធីរបស់ IFAD ប្រចាំនៅកម្ពុជា បានមានប្រសាសន៏ថា គំរោងនេះមិនត្រឹមតែជួយបង្កើនចំនូលប៉ុណ្ណោះទេ ប៉ុន្តែនឹងផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមកិច្ចដោយមានចីរភាព នាពេលអនាគត ។ លោកបានកត់សំគាល់ថា នេះជាលើកទីមួយហើយដែល IFAD បានកំនត់គោលដៅយកប្រជាជនក្រីក្ររស់នៅតំបន់ឆ្ងាយដាច់ស្រយាលនៅកម្ពុជា ។

សេចក្តីប្រកាសព័ត៌មានមួយរបស់ IFAD បានបញ្ជាក់ថា សង្គ្រាម និងជំលោះផ្ទៃក្នុងជាច្រើនទសវត្សរ៏ បានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដ៏ក្រីក្រមួយក្នុងពិភពលោក ។ គំរោងកំនត់យកខេត្ត ៣ ជាគោលដៅ គឺ ក្រចេះ ព្រះវិហារ និង រតនៈគីរី ដែលជាខេត្តក្រីក្រជាងគេនៅកម្ពុជា ។ គំរោងកែលំអជីវភាពនៅជនបទនេះ ដែលគ្រោងជួយដល់ប្រជាជន ២២,៦០០ គ្រួសារ នឹងបានទទួលមូលនិធិមួយចំណែកពីជំនួយហិរញ្ញវត្ថុឥតសំណងរបស់ IFAD ចំនួន ៩,៥លានដុល្លារ ។ គំរោងនេះ ក៏នឹងបានទទួលមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីអភិវឌ្ឍន៏ អង្គការសហប្រជាជាតិ (UNDP) ផងដែរ ។

***Cambodia could become leading rice exporter by next year***: Cambodia could achieve its ambition to become one of the world's leading milled rice exporters by 2008 if it has sufficient capital to buy unmilled rice from local farmers, local media reported June 1st. Cambodian local mills currently require 40 million U.S. dollars in capital to purchase unmilled rice from farmers to raise stocks for production of milled rice, the Rasmei Kampuchea newspaper quoted Pu Puy, president of the Rice Milling Association of Cambodia, as saying.

Cambodian farmers annually export more than one million tons of unmilled rice, particularly to neighboring Vietnam and Thailand, Pu Puy added. "We need around 40 million U.S. dollars, but the capital we have collected is only 10 million U.S. dollars," he said. "If we have adequate capital, we can export milled rice to the world market by 2008 or 2009." He stressed that the country's 280 mills, which have an average capital of 30,000 USD to 100,000 USD each, can currently buy and stock only enough unmilled rice to serve local markets and small-scale exports, the Rasmei Kampuchea said.

More than 80 percent of Cambodia's population are farmers, who enjoy a generally favorable climate, so they could produce a surplus of over one million tons of unmilled rice annually, but up until now they have not exported as much milled rice to the world markets as other producers due to a shortage of capital, he added. *(Cited from Xinhua, 1st June 2007)*

***Cambodia: Project to Help Rural Poor:*** The United Nations International Fund for Agricultural Development (IFAD) has announced that it will support a new $11.5 million development project in Cambodia aimed at helping the rural poor. "The project will not only boost incomes, it will also lay foundations for sustainable social and economic development in the future," said Youqiong Wang, IFAD's country programme manager for Cambodia, noting that it is the agency's first to target the poor ethnic population living in remote areas of the country.

Decades of war and internal strife have made Cambodia one of the world's poorer countries. The three provinces that the project is targeting – Kratie, Preah Vihear and Ratanakiri – are among the poorest in the country, IFAD said in a news release. The Rural Livelihoods Improvement Project, set to involve 22,600 rural households in the border provinces, will be financed partly by a grant of $9.5 million from IFAD. It will also receive funding from the Royal Government of Cambodia and the UN Development Programme (UNDP). *(Cited from www.scoop.co.nz, 31st May 2007)*